ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ សុក្រ ១១ រោច ខែ កត្តិក ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីកិច្ចពិភាក្សាការងារវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម Lyu Xinhua ប្រធានក្រុមប្រឹក្សាជំរុញកិច្ចសហប្រតិបត្តិការត្បូង-ត្បូង នៃសាធារណរដ្ឋប្រជាមានិតចិន

នារសៀលថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបពិភាក្សាការងារជាមួយឯកឧត្តម Lyu Xinhua ប្រធានក្រុមប្រឹក្សាជំរុញកិច្ចសហប្រតិបត្តិការត្បូង-ត្បូង (Council for Promoting South-South Cooperation) នៃសាធារណរដ្ឋប្រជាមានិតចិន ដោយមានវត្តមានចូលរួមផងដែរពីសំណាក់ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, និងឯកឧត្តម Wang Wentian ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា ។

នៅក្នុងឱកាសជំនួបពិភាក្សានោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះឯកឧត្តម Lyu Xinhua ប្រធានក្រុមប្រឹក្សាជំរុញកិច្ចសហប្រតិបត្តិការត្បូង-ត្បូងនៃសាធារណរដ្ឋប្រជាមានិតចិន និងប្រតិភូអមដំណើរ ដែលបានឆ្លៀតពេលដ៏មានតម្លៃអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា។ ទស្សនកិច្ចជាបន្តបន្ទាប់របស់គណៈប្រតិភូជាន់ខ្ពស់ចិននៅកម្ពុជា បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៃចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ ដែលពីមួយថ្ងៃទៅមួយថ្ងៃត្រូវបានពង្រឹង និងពង្រីកឥតឈប់ឈរ។ បច្ចុប្បន្ន បើនិយាយពីទំនាក់ទំនងក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយកម្ពុជា ប្រទេសចិនឈរនៅលំដាប់ទី ១ លើវិស័យជាច្រើន ដូចជា ការវិនិយោគ ទំហំពាណិជ្ជកម្មទ្វេភាគី និងទេសចរណ៍ជាដើម។ ទន្ទឹមនេះ ទំហំហិរញ្ញប្បទានសហប្រតិបត្តិការពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនរាជរដ្ឋាភិបាលកម្ពុជា ទាំងឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណង ក៏ឈរនៅលំដាប់ទី ១ ផងដែរ។

ឯកឧត្តម Lyu Xinhua បានជម្រាបឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ថា ក្រុមប្រឹក្សាជំរុញកិច្ចសហប្រតិបត្តិការត្បូង-ត្បូង នៃសាធារណរដ្ឋប្រជាមានិតចិន ត្រូវបានបង្កើតឡើងកាលពីឆ្នាំ ២០១៤ និងជាស្ថាប័នមួយដែលបំពេញបេសកកម្មតាមការតម្រង់ទិសរបស់ក្រសួងការបរទេសចិន។ ក្រុមប្រឹក្សានេះ គឺជាស្ពានតភ្ជាប់រវាងក្រុមហ៊ុន និងស្ថាប័ន នៃប្រទេសចិន ជាមួយក្រុមហ៊ុន និងស្ថាប័ន នៃប្រទេសកំពុងអភិវឌ្ឍន៍ ដោយមានមុខងារជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងវិស័យជាច្រើន មានដូចជា៖ វិស័យនយោបាយ សេដ្ឋកិច្ច

ពាណិជ្ជកម្ម វប្បធម៌ អប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ជាដើម។ ខណៈដែលកម្ពុជាគឺជាមិត្តដ៏ជិតស្និទ្ធបំផុតមួយរបស់ប្រទេសចិន និងប្រទេសយើងទាំងពីរមានទំនាក់ទំនងល្អជាប្រពៃណី ជាពិសេស ទំនាក់ទំនងដ៏វិសេសវិសាលរវាង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាមួយឯកឧត្តម Xi Jinping ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន, រដ្ឋាភិបាលចិនគាំទ្រយ៉ាងពេញទំហឹង និងជំរុញក្រុមហ៊ុនចិនឱ្យមកវិនិយោគនៅកម្ពុជាកាន់តែច្រើនឡើងថែមទៀត។

ឯកឧត្តម Lyu Xinhua បានសង្កេតឃើញថា មានក្រុមហ៊ុនចិនរាប់ពាន់បានមកដាក់ទុនវិនិយោគនៅកម្ពុជា ដែលមានគម្រោងវិនិយោគគ្របដណ្តប់ស្ទើរតែលើគ្រប់វិស័យ។ មានក្រុមហ៊ុនចិនជាច្រើនទៀត ក៏មានចំណាប់អារម្មណ៍មកវិនិយោគនៅកម្ពុជាដែរ។ ជាមួយគ្នានេះ ឯកឧត្តម Lyu Xinhua យល់ឃើញថា ការវិនិយោគលើធនធានមនុស្សដើរតួនាទីយ៉ាងសំខាន់ និងជាកត្តាគន្លឹះមួយរួមចំណែកក្នុងការជួយទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សាជំរុញកិច្ចសហប្រតិបត្តិការត្បូង-ត្បូងនៃសាធារណរដ្ឋប្រជាមានិតចិន ក៏លើកទឹកចិត្តឱ្យក្រុមហ៊ុនចិនវិនិយោគផងដែរលើគម្រោងបង្កើតសាលារៀនអន្តរជាតិនៅកម្ពុជា ដើម្បីជួយបណ្តុះបណ្តាលកុមារ និងយុវជននៅកម្ពុជា។

ជាការឆ្លើយតប ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់ថា កម្ពុជា និងចិន គឺជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងជាដៃគូកសាងសហគមន៍ជោគវាសនាតែមួយ។ កម្រិតនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរនាពេលបច្ចុប្បន្នបានឈានដល់កម្រិតកំពូលដែលមិនធ្លាប់មានពីមុនមក។ ចំពោះការវិនិយោគផ្ទាល់ពីបរទេស កន្លងមកក្នុងមួយឆ្នាំៗ មានក្រុមហ៊ុនចិនរាប់រយបានចុះបញ្ជីវិនិយោគនៅកម្ពុជា ដែលមានដើមទុនវិនិយោគរាប់ពាន់លានដុល្លារអាមេរិក ។ រាជរដ្ឋាភិបាលកម្ពុជាស្វាគមន៍គម្រោងវិនិយោគថ្មីបន្ថែមទៀតពីប្រទេសចិន ខណៈដែលកម្ពុជានៅមានសក្តានុពល និងកាលានុវត្តភាពជាច្រើនទៀតក្នុងការវិនិយោគ។ ដើម្បីទាក់ទាញ និងជំរុញការវិនិយោគ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំធ្វើកំណែទម្រង់លើគ្រប់វិស័យ ទាំងក្នុងក្របខ័ណ្ឌគោលនយោបាយ គតិយុត្ត និងបច្ចេកទេស ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជាក៏បានត្រៀមខ្លួនជាស្រេចដើម្បីសហការជាមួយភាគីចិន។ នាពេលឆាប់ៗខាងមុខនេះ ភាគីទាំងពីរនឹងរួមគ្នារៀបចំវេទិកាសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា-ចិន និងបង្កើតយន្តការសម្របសម្រួលមួយដើម្បីជំរុញ និងទាក់ទាញការវិនិយោគ។

ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះរដ្ឋាភិបាល និងប្រជាជនចិន ដែលបានជួយឧបត្ថម្ភគាំទ្រដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ គម្រោងវិនិយោគពីប្រទេសចិនបានរួមវិភាគទានយ៉ាងធំធេងដល់ការអភិវឌ្ឍនៅកម្ពុជា និងរួមចំណែកជួយឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់និងប្រកបដោយចីរភាព ព្រមទាំងបានបង្កើតការងារ និងផ្តល់ប្រភពចំណូលសម្រាប់ទ្រទ្រង់ជីវភាពរបស់ប្រជាជនកម្ពុជា៕